# Tips to Avoid Home Health Fraud

មេឌិឃារ បង់ថ្លៃ សេវាកម្មសុខភាពនៃគេហដ្ឋាន បើប្រសិនជា អ្នក “ចេញពីផ្ទះមិនរួច” -“homebound” (គឺមិនអាចចេញ ពីផ្ទះ ដោយគ្មាន ការប្រឹងប្រែងខ្លាំងក្លា) ហើយត្រូវការសេវាកម្មមួយ ក្នុងបណ្តា សេវាកម្ម ដូចតទៅ៖ ការព្យាបាលផ្នែករាងកាយខាងក្រៅ (physical therapy), ការព្យាបាលផ្នែកមុខរបរ (occupational therapy) ការព្យាបាលផ្នែកពាក្យសំដី (speech therapy) ឬ សេវាកម្មផ្នែកជំនាញគិលានុបដ្ឋា (skilled nursing) ។ មេឌិឃារ **មិន** បង់ផ្នែកការថែទាំផ្ទាល់ខ្លួនធម្មតា( ជួយងូតទឹក, ស្លៀកពាក់ ។ល។) ឬ ការបម្រើ ជាប្រចាំ ដូចជា ការពិនិត្យមើលសម្ពាធឈាម ឬ រោគសញ្ញាសំខាន់ៗផ្សេងៗទៀត ជា សេវាកម្មសុខភាពនៃគេហដ្ឋាន នោះទេ បើប្រសិនជា អ្នកមិនបានទទួល ការព្យាបាល (therapy) ឬ ជំនាញគិលានុបដ្ឋា ផងដែរទេនោះ ។

**តនៅនេះ គឺជា ចំណុចសំខាន់ៗខ្លះៗ ដើម្បីចៀសវាង ការក្លែងបន្លំសុខភាពនៃគេហដ្ឋាន**

## <u>ចូរកុំ...</u>

- **ចូរកុំ** អោយលេខមេឌិឃារ របស់អ្នកទៅជនដែលអ្នកមិនស្គាល់ ជាពិសេស ជនដែលហៅតាមទូរស័ព្ទ, មកដល់មាត់ទ្វារ, ឬ ផ្តល់ សេវាកម្ម “ឥតគិតថ្លៃ” ដើម្បីដូរយក លេខមេឌិឃារ របស់អ្នក នោះឡើយ ។ សេវាកម្ម “ឥតគិតថ្លៃ” ដូចជា បទបង្ហាញ, (presentations), ថ្នាក់ហាត់ប្រាណ និង ការពិនិត្យសុខភាព (health screenings)មិនតម្រូវអោយមាន លេខ មេឌិឃារ របស់អ្នកទេ!

- **ចូរកុំ** ទទួលយកសេវាកម្ម ពីជនដែលទៅមើលអ្នក ដោយមិនបានប្រាប់ទុកជាមុន ទោះបីជា គេពោលថា វេជ្ជបណ្ឌិតរបស់អ្នកបានបញ្ជូនពួកគេមកក៏ដោយ!

- **ចូរកុំ** ចុះឈ្មោះ (sign up) ទទួលយក សេវាកម្មសុខភាពនៃគេហដ្ឋាន នៅកន្លែង បទបង្ហាញ ឬ ព្រឹត្តិការណ៍ណាមួយ នោះឡើយ ។

- **ចូរកុំ** ចុះហត្ថលេខាលើ សន្លឹកពេលវេលា ឬ ក្រដាសស្នាម ផ្សេងៗទៀត ដោយពុំបានអានវា ឬ ចុះហត្ថលេខាលើក្រដាសស្នាម ដែលនៅចន្លោះទទេ នោះឡើយ ។

# Tips to Avoid Home Health Fraud

## <u>ចូរធ្វើ...</u>

- **ចូរ** ទាក់ទងគ្រូពេទ្យ(doctor) របស់អ្នក បើអ្នកគិតថា អ្នកប្រហែលជាត្រូវការ សេវាកម្មសុខភាពនៃគេហដ្ឋាន។ គ្រូពេទ្យរបស់អ្នកគប្បី បញ្ជាទិញ (order) សេវាកម្ម ឬសម្ភារៈដែលអ្នកត្រូវការ។

- **ចូរ** សាកសួរ ភ្នាក់ងារសុខភាពនៃគេហដ្ឋាន សម្រាប់ក្រដាសចំឡងនៃ **គំរោងថែទាំ** របស់អ្នក នៅពេលដែលអ្នកត្រូវបានវាយតម្លៃ ដើម្បី សេវាកម្មសុខភាពនៃគេហដ្ឋាន។ (នេះជា សេចក្តីពន្យល់មួយ ស្តីពី សេវាកម្មអ្វី ដែលភ្នាក់ងារសុខភាពនៃគេហដ្ឋាននឹងផ្តល់អោយ ព្រមទាំង មូលហេតុដែលអ្នកត្រូវការវា។) ទាំងអ្នក ទាំងគ្រូពេទ្យរបស់អ្នក គួរពិនិត្យមើល ក្រដាសចំឡង នៃ **គំរោងថែទាំ** របស់អ្នក ឡើងវិញ មុនពេលអ្នក ទទួល សេវាកម្មសុខភាពនៃគេហដ្ឋាន។

- **ចូរ** អានកំណត់ហេតុសង្ខេបមេឌិយារ - Medicare Summary Notice (MSN) របស់អ្នក ឬ សេចក្តីពន្យល់អំពីផលកម្រៃ - Explanation of Benefits (EOB) ពីក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នក។ ចូរ ពិនិត្យមើល សេវាកម្មដែលអ្នកមិនបានទទួល, សេវាកម្មដែល មិនបានបញ្ជាទិញដោយ គ្រូពេទ្យរបស់អ្នក ឬ កំហុសនៃថ្លៃចំណាយផ្សេងៗទៀត។

កម្មវិធី SMP (Senior Medicare Patrol – ការត្រួតពិនិត្យមេឌិយារមនុស្សចាស់) រដ្ឋអ៊ីល្លីណយ អប់រំ អ្នកប្រើប្រាស់ អំពី ការក្លែងបន្លំ, កាកសំណល់ និង ការរំលោភ (abuse) លើការថែទាំសុខភាព។ បើអ្នកមានសំណួរ ស្តីពី ការទាមទារ លើ កំណត់ហេតុសង្ខេបមេឌិយារ ឬ សេចក្តីពន្យល់នៃផលកម្រៃ, ចូរហៅទៅ កម្មវិធី Illinois SMP លេខ **(800)699-9043**។ ពត៌មានទាក់ទងអំពី កម្មវិធី Illinois SMP គឺអាចរកបាននៅលើ វ៉ើបសៃ របស់យើង **www.illinoissmp.org** ផងដែរ។

ឯកសារនេះ ត្រូវបានឧបត្ថម្ភឡើង មួយផ្នែក ដោយលេខថវិកា 90MP0026 នៃរដ្ឋបាលសហរដ្ឋ ស្តីពី មនុស្សចាស់ជរា, ក្រសួងសេវាកម្ម សុខភាព និង ក្រសួង មនុស្សធម៌។ អ្នកទទួលប្រាក់ ដែលកំពុងអនុវត្ត កិច្ចការ ក្រោមកិច្ចធានារ៉ាប់រងរបស់រដ្ឋាភិបាល ត្រូវបានលើកទឹកចិត្ត ដើម្បី បញ្ចេញគំហើញ និង សេចក្តីសន្និដ្ឋាន របស់គេ ដោយសេរី។ ដូច្នេះ ទស្សនៈយល់ឃើញ ឬ គំនិតយោបល់ ទាំងឡាយ គឺមិនមែន ជាការចាំបាច់ ដើម្បី តំណាងអោយ រដ្ឋបាលផ្លូវការ ស្តីពី គោលនយោបាយមនុស្សចាស់ជរា នោះឡើយ។